**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការពារជាតិ**

លេខ ២៤៤/សរណ ២០១៩

ថ្ងៃចន្ទ ៤រោច ខែភទ្របទ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០១៩

# សេចក្តីជូនដំណឹង

## ស្តីពីការជ្រើសរើសនិស្សិត សិស្សទាំងពីរភេទ ប្រឡងចូលសិក្សាវគ្គនាយទាហានសកម្ម ជំនាន់ទី២៤ នាយទាហានទ័ពជើងគោកជំនាន់ទី១២ នាយទាហានបន្តវេនជំនាន់ទី១៣ និងនាយទាហានជំនាញបច្ចេកទេសយោធា

**យោង** ប្រកាសលេខ ០៦៩-០៧០-០៧១ ប្រក.កពជ ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៩ របស់ក្រសួងការពារជាតិ ស្តីពីការជ្រើសរើស និងហ្វឹកហ្វឺននាយទាហានសកម្មជំនាន់ទី២៤ នាយទាហានទ័ពជើងគោកជំនាន់ទី១២ នាយទាហានបន្តវេនជំនាន់ទី១៣

- ប្រកាសលេខ ០៤៦ ប្រក.កពជ ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៩ របស់ក្រសួងការពារជាតិ ស្តីពីការជ្រើសរើសនិស្សិត សិស្សមកបណ្តុះបណ្តាលជំនាញបច្ចេកទេសយោធា នៅវិទ្យាស្ថានបច្ចេកទេសយោធាតេជោ ហ៊ុន សែន ។

គណៈកម្មការជ្រើសរើស និងត្រួតពិនិត្យលក្ខណសម្បត្តិសិក្ខាកាមមកបណ្តុះបណ្តាលនៅក្នុង និងក្រៅប្រទេស សូមជូនដំណឹងដល់បេក្ខជននិស្សិត សិស្សទាំងពីរភេទ ដែលស្ម័គ្រចិត្តចូលបម្រើការងារក្នុងក្របខ័ណ្ឌ នៃកងយោធពលខេមរភូមិន្ទ ត្រូវមកទំនាក់ទំនងនិងសុំដាក់ពាក្យចុះឈ្មោះចូលប្រឡងជ្រើសរើសវគ្គនាយទាហាន តាមប្រកាសលេខ០៦៩-០៧០-០៧១ និង០៤៦ របស់ក្រសួងការពារជាតិ ដូចមានលក្ខខណ្ឌជ្រើសរើស ទីកន្លែងនិងកាលបរិច្ឆេទដូចខាងក្រោម៖

**ក.លក្ខខណ្ឌជ្រើសរើស**

១.សញ្ជាតិខ្មែរ

២.មានអាយុពី១៨ឆ្នាំ ដល់២៥ឆ្នាំ នៅលីវ គិតត្រឹមថ្ងៃដាក់ពាក្យសុំចុះឈ្មោះចូលប្រឡង

៣.មានកាយសម្បទាគ្រប់គ្រាន់តាមតម្រូវការ ដើម្បីបំពេញមុខងារ

៤.មិនធ្លាប់ត្រូវបានតុលាការផ្តន្ទាទោស

៥.មានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិឡើងទៅ

៦.បុរសមានកម្ពស់ ១៦០ស.ម និងនារីមានកម្ពស់ ១៥០ស.ម ឡើងទៅ

**ខ.ទីកន្លែង និងកាលបរិច្ឆេទ**

-ការចែកពាក្យនិងទទួលពាក្យសុំចុះឈ្មោះចូលប្រឡងនឹងត្រូវចាប់ផ្តើមពីថ្ងៃទី១៩ ខែកញ្ញា ដល់ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៩

-ទីកន្លែងចែកពាក្យ និងទទួលពាក្យ នៅមណ្ឌលជ្រើសរើសសាកលវិទ្យាល័យការពារជាតិ និងនៅយោធភូមិភាគទី១ ទី២ ទី៣ ទី៤ និងទី៥ ។

អាសយដ្ឋានទំនាក់ទំនងតាមរយៈ វិបសាយ អ៊ីម៉ែល ទូរស័ព្ទលេខ៖

- វិបសាយ WWW : cot.mod.gov.kh (Facebook): RCAF Cambodia
- អ៊ីម៉ែល Email : cotcambodia@mod.gov.kh
- ទូរស័ព្ទលេខ ០១២ ៩៥ ៧៤ ៨៣ / ០១៦ ៨៤ ៦៤ ៥៣/ ០៩៧ ៥៦ ៥៦ ៤១៣

បេក្ខជននិស្សិត សិស្សទាំងពីរភេទត្រូវមកទំនាក់ទំនងសាកសួរព័ត៌មានលម្អិត និងបំពេញទម្រង់បែបបទផ្សេងៗ នៅទីកន្លែងទទួលពាក្យនិងដាក់ពាក្យ នៅរៀងរាល់ម៉ោងធ្វើការ ។

**រដ្ឋលេខាធិការ ក្រសួងការពារជាតិ**
**និងជាប្រធានគណៈកម្មការ ✓**

នាយឧត្តមសេនីយ៍.ត្លុង_ស៊ីផាន